# តើខ្ញុំគួរដឹងអ្វីខ្លះអំពីការក្លាយជាសមាជិក Herbalife Nutrition ម្នាក់?

### តើខ្ញុំអាចចូលរួមយ៉ាងដូចម្តេច?

ក្នុងនាមជាសមាជិក Herbalife Nutrition ម្នាក់ អ្នកអាច៖

- ទិញផលិតផល Herbalife Nutrition ក្នុងអត្រាបញ្ចុះតម្លៃសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងក្រុមគ្រួសារទាំងមូល។
- ចូលរួមក្នុងឱកាសអាជីវកម្មតាមរយៈការលក់ផលិតផល Herbalife Nutrition ដើម្បីទទួលបានចំណូលលក់រាយ។
- ចូលរួមក្នុងឱកាសអាជីវកម្មតាមរយៈការជ្រើសរើសអ្នកដទៃដែលចង់ប្រើប្រាស់ ឬលក់ផលិតផល Herbalife Nutrition។

សមាជិកភាគច្រើនចូលរួមដើម្បីទទួលបានការបញ្ចុះតម្លៃលើការទិញផលិតផល Herbalife Nutrition តែប៉ុណ្ណោះ ហើយមិនចូលរួមក្នុងអាជីវកម្មទេ។ ជាលទ្ធផល ក្នុងឆ្នាំ 2020 សមាជិកជាទូទៅមិនបានទទួលប្រាក់កម្រៃពីក្រុមហ៊ុន Herbalife Nutrition ទេ។

### តើខ្ញុំត្រូវដឹងអ្វីខ្លះអំពីឱកាសអាជីវកម្មនេះ?

- គ្មានការតម្រូវអោយទិញអ្វីក្រៅពីកញ្ចប់សមាជិកភាពដំបូងនោះទេ ដែលត្រូវបានស្គាល់ថាជា កញ្ចប់សមាជិក Herbalife Nutrition (HMP) - (USD 34.67)
- សមាជិករីករាយនឹងការកំណត់កាលវិភាគរបស់ពួកគេដោយខ្លួនឯង និងការជ្រើសរើសរបៀប និងពេលវេលាធ្វើកិច្ចការរបស់ខ្លួន។
- មនុស្សភាគច្រើនចាប់ផ្តើមអាជីវកម្ម Herbalife Nutrition របស់ពួកគេក្រៅម៉ោង និងលក់ផលិតផលទៅអ្នកដែលពួកគេស្គាល់ ឬជួប ជាវិធីរកប្រាក់ចំណូលបន្ថែមបន្តិចបន្តួច។
- គ្មានការធានាថា អ្នកនឹងទទួលបានប្រាក់ចំណូលនោះទេ។ ដូចគ្នាទៅនឹងអ្នកធ្វើអាជីវកម្មដទៃទៀតដែរ សមាជិកខ្លះនឹងទទួលបានជោគជ័យ ខណៈដែលអ្នកខ្លះទៀតមិនជោគជ័យ។
- ការកសាងអាជីវកម្ម Herbalife Nutrition ដោយជោគជ័យត្រូវការជំនាញ ការខិតខំប្រឹងប្រែង និងពេលវេលា។

### តើខ្ញុំរកចំណូលបានដោយរបៀបណា?

អ្នកអាចរកបានចំណូលតាមរយៈការលក់ផលិតផល Herbalife Nutrition ដែលអ្នកទិញក្នុងអត្រាបញ្ចុះតម្លៃ។ ការបញ្ចុះតម្លៃដែលអ្នកទទួលបានដំបូងគឺប្រមាណ 25%។ អ្នកលក់បានកាន់តែច្រើនអ្នកទទួលបានការបញ្ចុះតម្លៃកាន់តែខ្ពស់ គឺរហូតដល់អតិបរមា 50%។ ជាឧទាហរណ៍ ការបញ្ចុះតម្លៃដំបូងសម្រាប់ Formula 1 ដែលជាផលិតផលលក់ដាច់បំផុតរបស់ Herbalife Nutrition ត្រូវបានបង្ហាញនៅខាងស្តាំនេះ៖




| | |
|---|---|
| តម្លៃលក់រាយដែលបានកំណត់ | USD 34.67 |
| តម្លៃសមាជិក<br>*(ជាមួយនឹងការបញ្ចុះតម្លៃ មិនទាន់បូកបញ្ចូលថ្លៃដឹកជញ្ជូន និងពន្ធ)* | USD 27.59 |
| ប្រាក់ចំណេញសក្តានុពល | **USD 7.08** |

- ប្រសិនបើអ្នកបិតក្នុងកម្រិតបញ្ចុះតម្លៃដំបូង ហើយលក់ផលិតផលនេះបាន 10 កំប៉ុង ក្នុងតម្លៃលក់រាយដែលបានកំណត់ ដោយមិនទាន់គិតពីថ្លៃដឹកជញ្ជូន និងពន្ធ អ្នកអាចរកបាន USD 70.80 មុនដាត់ទាត់ចំណាយ។
- អ្នកក៏អាចរកចំណូលបានពីការលក់របស់មនុស្សដែលអ្នកបានឧបត្ថម្ភផងដែរ។
- អ្នកមិនអាចរកចំណូលបានដោយគ្រាន់តែជ្រើសរើស ឬឧបត្ថម្ភនរណាម្នាក់នោះទេ។

### បន្ថែមទៅលើប្រាក់ចំណូលលក់រាយ តើខ្ញុំអាចរកបានប៉ុន្មានពីការលក់របស់សមាជិកដែលខ្ញុំឧបត្ថម្ភ?

នៅក្នុងឆ្នាំ 2020 មានសមាជិក 6,261 នាក់ ដែលបានក្លាយជាសមាជិករយៈពេលយ៉ាងហោច 1 (មួយ) ឆ្នាំពេញ។ បន្ថែមលើចំណូលលក់រាយ មានសមាជិកចំនួន 17% ឬស្មើនឹង 1,095 នាក់ ក្នុងចំណោមពួកគេរកបានកម្រៃជើងសារ ឬប្រាក់ឧបត្ថម្ភពីការលក់របស់សមាជិកដែលពួកគេបានឧបត្ថម្ភ។ នេះជាអ្វីដែលពួកគេរកបាន មុនដាត់ទាត់ចំណាយ៖

| សមាជិក 1 ឆ្នាំឡើងទៅ (1,095 នាក់) |
|---|
| 50% (ប្រមាណ 548 នាក់) រកចំណូលបានច្រើនជាង USD 397 |
| 10% (ប្រមាណ 110 នាក់) កំពូលៗ រកចំណូលបានច្រើនជាង USD 6,270 |

### ចុះបើវាមិនសមប្រកបសម្រាប់ខ្ញុំ?

- អ្នកអាចរំសាយសមាជិកភាពរបស់អ្នកនៅពេលណាក៏បាន។ ប្រសិនបើអ្នកបិតក្នុងរយៈពេល 90 ថ្ងៃដំបូង អ្នកអាចរំសាយ និងទទួលបានការប្រគល់ប្រាក់ជូនវិញពេញលេញលើកញ្ចប់សមាជិក Herbalife Nutrition របស់អ្នក។
- ប្រសិនបើអ្នករំសាយសមាជិកភាពរបស់អ្នក អ្នកអាចប្រគល់ផលិតផលដែលមិនទាន់បានបើក ដែលអ្នកបានទិញក្នុងរយៈពេលមួយឆ្នាំចុងក្រោយមកក្រុមហ៊ុនវិញ ដើម្បីទទួលបានការប្រគល់ប្រាក់ជូនវិញពេញលេញ។ យើងនឹងចេញថ្លៃចំណាយក្នុងការដឹកជញ្ជូនទៀតផង។

សូមទាក់ទងតាមរយៈលេខទូរស័ព្ទ (855) 23-999-268 សម្រាប់ព័ត៌មានបន្ថែម។

## របាយការណ៍ស្តីអំពីសំណងជាមធ្យមឆ្នាំ 2020 សម្រាប់ប្រទេសកម្ពុជា

HERBALIFE NUTRITION